ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

ទីស្ដីការគណៈរដ្ឋមន្ត្រី

# ក្រុមប្រឹក្សាសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ (ក.ស.វ.)

**ECONOMIC, SOCIAL AND CULTURAL COUNCIL (ECOSOCC)**







# វិភាគស្ថានភាព
# សេដ្ឋកិច្ច សង្គម និងវប្បធម៌

## ប្រចាំត្រីមាសទី៣ ឆ្នាំ២០២១



# មាតិកា


១- វិភាគស្ថានភាពសេដ្ឋកិច្ច សង្គម និងវប្បធម៌កម្ពុជា ប្រចាំត្រីមាសទី៣ ឆ្នាំ២០២១.......... ១

២- តារាងទី១៖ ស្ថានភាពសន្ទស្សន៍ថ្លៃទំនិញប្រើប្រាស់ និងអត្រាប្តូរប្រាក់ .......... ១០

៣- តារាងទី២៖ ស្ថានភាពថវិកាជាតិ.......... ១៣

៤- តារាងទី៣៖ ស្ថានភាពរូបិយវត្ថុ.......... ១៥

៥- តារាងទី៤៖ ស្ថានភាពកសិកម្ម ឧស្សាហកម្ម សេវាកម្ម និងវប្បធម៌ .......... ១៧

៦- តារាងទី៥៖ ស្ថានភាពជញ្ជីងពាណិជ្ជកម្ម .......... ១៩

# វិភាគស្ថានភាពសេដ្ឋកិច្ច សង្គម និងវប្បធម៌កម្ពុជា
# ប្រចាំត្រីមាសទី៣ ឆ្នាំ២០២១*

របាយការណ៍វិភាគនេះជាលទ្ធផលនៃកិច្ចប្រជុំពេញអង្គនៃក្រុមប្រឹក្សាសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌(ក.ស.វ) ដើម្បីពិភាក្សាលើស្ថានភាពសេដ្ឋកិច្ច សង្គម និងវប្បធម៌ ដែលបានប្រព្រឹត្តទៅនាថ្ងៃសុក្រ ១៤រោច ខែកត្តិក ឆ្នាំឆ្លូវ ត្រីស័ក ព.ស.២៥៦៥ ត្រូវនឹងថ្ងៃទី០៣ ខែធ្នូ ឆ្នាំ២០២១ ក្រោមអធិបតីភាព**ឯកឧត្តមទេសរដ្ឋមន្ត្រី យឹម ឈុលឡា** ប្រធានក.ស.វ. ដែលមានសមាសភាពចូលរួម អនុប្រធានប្រចាំការ អនុប្រធានក.ស.វ. ឯកឧត្តម សារ៉ាក់ ខាន់ រដ្ឋមន្ត្រីប្រតិភូអមនាយករដ្ឋមន្ត្រីទទួលបន្ទុកជួយនាយករដ្ឋមន្ត្រីលើការងារក.ស.វ. សមាជិក សមាជិកា ទីប្រឹក្សាបច្ចេកទេស មន្ត្រីអគ្គលេខាធិការដ្ឋានមួយចំនួននៃក.ស.វ និងក្រុមការងារបច្ចេកទេសរៀបចំសេចក្តីព្រាងរបាយការណ៍ស្តីពីស្ថានភាពសេដ្ឋកិច្ច សង្គម និងវប្បធម៌ តាមរយៈប្រព័ន្ធហ្សូម (Zoom)។ ការរៀបចំរបាយការណ៍នេះបានផ្អែកលើមូលដ្ឋានព័ត៌មានទិន្នន័យពីក្រសួង ស្ថាប័ន ពាក់ព័ន្ធ ព្រមទាំងមតិយោបល់ដែលជាធាតុចូលផ្សេងៗទៀតពីអង្គប្រជុំទាំងមូល។

## ១. ស្ថានភាពសន្ទស្សន៍ថ្លៃទំនិញប្រើប្រាស់និងអត្រាប្តូរប្រាក់(តារាង១)

➡ នាត្រីមាសទី៣ ឆ្នាំ២០២១ សន្ទស្សន៍ថ្លៃទំនិញប្រើប្រាស់កើនឡើង១,៣% ធៀបនឹងត្រីមាសមុន និងកើនឡើង៣,២% ធៀបនឹងត្រីមាសដូចគ្នាឆ្នាំមុន។

តារាង១.១. បម្រែបម្រួលថ្លៃធៀបនឹងត្រីមាសដូចគ្នាឆ្នាំមុនសម្រាប់ក្រុមទំនិញនិងមុខទំនិញមួយចំនួន

| *ក្រុមទំនិញ:* | | *មុខទំនិញ:* | |
|---|---|---|---|
| សំលៀកបំពាក់ និងស្បែកជើង | +៥,៧% | បន្លែ | +៥,៦% |
| ទំនិញ និងសេវាកម្មផ្សេងៗ | +៤,៨% | សាច់ជ្រូក | +៤,៦% |
| ម្ហូបអាហារ | +៣,១% | ត្រីស្រស់ | +៤,០% |
| ផ្ទះសំបែង ទឹក អគ្គិសនី ឧស្ម័ន និងឥន្ធនៈផ្សេងទៀត | +២,៨% | ផ្លែឈើ | +៣,១% |
| សុខាភិបាល | +១,៩% | សាច់គោស្រស់ | +១,៧% |
| គ្រឿងសង្ហារិម និងសម្ភារៈប្រើប្រាស់ | +១,៥% | សាច់មាន់ស្រស់ | +១,៤% |
| ភេសជ្ជៈមានជាតិស្រវឹង និងថ្នាំជក់ | +១,៤% | អង្ករ | +០,៨% |
| ភោជនីយដ្ឋាន | +០,៨% | | |
| ការកម្សាន្ត និងវប្បធម៌ | +០,៤% | | |

តារាង១.២. អត្រាប្តូរប្រាក់

| *បរិយាយ* | *ត្រីមាសទី៣ ២០២១* | *ត្រីមាសទី២ ២០២១* | *ត្រីមាសទី៣ ២០២០* | *បរិយាយ* | *ត្រីមាសទី៣ ២០២១* | *ត្រីមាសទី២ ២០២១* | *ត្រីមាសទី៣ ២០២០* |
|---|---|---|---|---|---|---|---|
| **៛/ដុល្លារ** | ៤ ០៧៩៛/$ | ៤ ០៧៥៛/$ | ៤ ១០០៛/$ | **បាត/ដុល្លារ** | ៣៣,៩បាត/$ | ៣២,១បាត/$ | ៣១,៦បាត/$ |
| **៛/បាត** | ១២០៛/បាត | ១២៧៛/បាត | ១៣០៛/បាត | **ដុង/ដុល្លារ** | ២២៧៣៥ដុង/$ | ២២ ៩៩៧ដុង/$ | ២៣១៦៣ដុង/$ |
| **៛/ដុង** | ០,១៧៩៛/ដុង | ០,១៧៧៛/ដុង | ០,១៧៧៛/ដុង | **យ៉ន់/ដុល្លារ** | ៦,៥យ៉ន់/$ | ៦,៥យ៉ន់/$ | ៦,៨យ៉ន់/$ |

* ការវិភាគជាសំណេរដកស្រង់ចេញពីទិន្នន័យសំខាន់ៗប៉ុណ្ណោះ មិនគ្របដណ្តប់តួលេខទាំងអស់ទេ (មើលតារាងភ្ជាប់មកជាមួយ)។

* ដើម្បីមានសង្គតិភាពក្នុងការប្រើប្រាស់លេខខ្មែរ និងអន្តរជាតិ សញ្ញាក្បៀសនៅក្នុងអត្ថបទ តាងឲ្យទសភាគ។ ប៉ុន្តែក្នុងតារាងលេខ (Excel) សញ្ញាក្បៀសតាងឲ្យខ្ទង់ពាន់ ឯសញ្ញាចុចជាទសភាគវិញ។

## ២. ស្ថានភាពថវិកាជាតិ( តារាង២ )

➡យោងតាមស្ថិតិរបស់រតនាគារជាតិ អគ្គនាយកដ្ឋានគយនិងរដ្ឋាករ និងអគ្គនាយកដ្ឋានពន្ធដារក្នុងត្រីមាសទី៣ ឆ្នាំ ២០២១ ថវិកាជាតិមានស្ថានភាពដូចខាងក្រោម:

ក្រាហ្វ ២.១. ចំណូលថវិកាជាតិ ឆ្នាំ ២០១៩ ដល់ ២០២១

(ប៊ីលានរៀល)




**២.១. ចំណូលថវិកាជាតិ** : អនុវត្តបាន ៤ ២៩៤,៨ ប៊ីលានរៀល គិតជាដុល្លារអាមេរិកស្មើ ១ ០៧៣,៧ លានដុល្លារ (*មធ្យមប្រចាំខែ ៨២,៧%នៃផែនការ*) ក្នុងនោះចំណូលចរន្តចំនួន ៤ ២៦៨,៣ ប៊ីលានរៀល គិតជាដុល្លារអាមេរិក ស្មើ ១ ០៦៧,១ លានដុល្លារ (*មធ្យមប្រចាំខែ ៨៦,៦% នៃផែនការ*) និងចំណូលមូលធនចំនួន ២៦,៥ ប៊ីលានរៀល គិតជាដុល្លារអាមេរិក ស្មើ ៦,៦ លានដុល្លារ (*មធ្យមប្រចាំខែ ២៣,៩% នៃផែនការ*) (តាមតួលេខរតនាគារជាតិ)។

➢បើធៀបនឹងត្រីមាសមុន ចំណូលថវិកាជាតិថយចុះ ២២,១% និងថយចុះ ១៧,៨% ធៀបនឹងត្រីមាសដូចគ្នាឆ្នាំ ២០២០។

➢នៅក្នុងចំណូលចរន្ត:

✓ចំណូលសារពើពន្ធមានចំនួន ៤ ៥៩០,០ ប៊ីលានរៀល ថយចុះ ១៩,៧% ធៀបនឹងត្រីមាសមុនប៉ុន្តែ កើនឡើង ៣,៨% ធៀបនឹងត្រីមាសដូចគ្នាឆ្នាំមុន (តាមតួលេខអគ្គនាយកដ្ឋានពន្ធដារ និងអគ្គនាយកដ្ឋានគយ)។ ចំណែកតាមតួលេខរតនាគារជាតិ ចំណូលសារពើពន្ធមានចំនួន ៣ ៩៩២,២ ប៊ីលានរៀលថយចុះ ២៣,០% ធៀបនឹងត្រីមាសមុនប៉ុន្តែ កើនឡើង ២,៧% ធៀបនឹងត្រីមាសដូចគ្នាឆ្នាំមុន។

✓ចំណូលមិនមែនសារពើពន្ធ មានចំនួន ២៧៤,៦ ប៊ីលានរៀលកើនឡើង ៧,៥% ធៀបនឹងត្រីមាសមុននិង កើនឡើង ៤,៣% ធៀបនឹងត្រីមាសដូចគ្នាឆ្នាំមុន(តាមតួលេខរតនាគារជាតិ)។

**តារាង២.១. មុខចំណូលមួយចំនួនក្នុងចំណូលសារពើពន្ធ និងចំណូលមិនមែនសារពើពន្ធ**

| **ចំណូលសារពើពន្ធ** (ក្នុងវង់ក្រចក:បម្រែបម្រួលធៀបនឹងត្រីមាសដូចគ្នាឆ្នាំមុន) | | **ចំណូលមិនមែនសារពើពន្ធ** (តាមតួលេខ រតនាគារជាតិ) (ក្នុងវង់ក្រចក:បម្រែបម្រួលធៀបនឹងត្រីមាសដូចគ្នាឆ្នាំមុន) | |
|---|---|---|---|
| ➢ ពន្ធ និងអាករគយ: :-០,៧% | (-១,៤%) | ➢អាជ្ញាបណ្ណក្នុងស្រុក : +៣០៥,២%<br>➢កម្រៃការគ្រប់គ្រងនិងទិដ្ឋាការនាំចេញ: -៨,៣% | +១៩,៥%<br>(+៤៦,៨%) |

| | | | |
|---|---|---|---|
| (អគ្គនាយកដ្ឋានគយ និងរដ្ឋាករ)<br>➢ ចំណូលពន្ធដារ: -៣២,១%<br>(អគ្គនាយកដ្ឋានពន្ធដារ) | (+៩,៣%) | ➢សម្បទានរ៉ែ: +១៥,៦%<br>➢អាកាសចរណ៍ស៊ីវិល: -៩,០%<br>➢ផលទុននៃសកម្មភាពទេសចរណ៍: -១៧,៧% | (+១៧,០%)<br>(-៦២,៤%)<br>(-៨១,៦%) |

**២.២. ចំណាយថវិកាជាតិ** : អនុវត្តបាន ៦ ៣៣២,៦ ប៊ីលានរៀល គិតជាដុល្លារអាមេរិកស្មើ ១ ៥៨៣,២ លានដុល្លារ (*មធ្យមប្រចាំខែ ១១៨% នៃផែនការ*) ក្នុងនោះ ចំណាយចរន្តចំនួន ៤ ៥៦៧,១ ប៊ីលានរៀល (*មធ្យមប្រចាំខែ ១៣១% នៃផែនការ*) និងចំណាយមូលធនមានចំនួន ១ ៧៦៥,៥ ប៊ីលានរៀល (តាមតួលេខ រតនាគារជាតិ)។

ក្រាហ្វ២.២. ចំណាយថវិកាជាតិ ឆ្នាំ ២០១៩ ដល់ ២០២១

(ប៊ីលានរៀល)




➢ចំណាយថវិកាជាតិកើនឡើង ៣៣,៤%ធៀបនឹងត្រីមាសមុននិងកើនឡើង ២៣,៨%ធៀបនឹងត្រីមាសដូចគ្នាឆ្នាំមុន។ ក្នុងនោះចំណាយចរន្តកើនឡើង ២៣,៩%ធៀបនឹងត្រីមាសមុននិង កើនឡើង ២១,២%ធៀបនឹងត្រីមាសដូចគ្នាឆ្នាំមុន។

**២.៣. សមតុល្យថវិកាជាតិ** : ថវិកាជាតិនាត្រីមាសទី១នេះ មានឱនភាពចំនួន ២ ០៣៧,៨ ប៊ីលានរៀល គិតជាដុល្លារអាមេរិក ស្មើ ៥០៩,៥ លានដុល្លារ (តួលេខរតនាគារជាតិ)។

## ៣. ស្ថានភាពរូបិយវត្ថុនិងអត្រាការប្រាក់ (តារាង៣)

➡ស្ថានភាពរូបិយវត្ថុ ក្នុងត្រីមាសទី៣ ឆ្នាំ២០២១មានលក្ខណៈដូចខាងក្រោម:

➢រូបិយវត្ថុ$M_2$ មានចំនួន ១៥២ ៨៧៥,១ ប៊ីលានរៀលមានការកើនឡើង៣,៣%ធៀបនឹងខែមុននិងកើនឡើង ១៥,៣%ធៀបនឹងខែដូចគ្នាឆ្នាំមុន។ **ការកើនឡើង$M_2$** ក្នុងត្រីមាសនេះ ជារួមបណ្តាលមកពី ការកើនឡើងនៃ រូបិយវត្ថុក្រៅគ្រឹះស្ថានទទួលប្រាក់បញ្ញើ ០,១% ប្រាក់បញ្ញើចរន្ត ៣,៨% និងប្រាក់បញ្ញើផ្សេងទៀត ៣,៦%។

## ក្រាហ្វ៣.១. សមាសធាតុរូបិយវត្ថុត្រីមាសទី៣ ឆ្នាំ២០២១




➢ក្នុងត្រីមាសនេះ ប្រាក់រៀលនៅក្នុង និងក្រៅគ្រឹះស្ថានទទួលប្រាក់បញ្ញើរមានចំនួន១៧,៤% និងប្រាក់បញ្ញើជារូបិយបណ្ណមានចំនួន៨២,៦% នៃរូបិយវត្ថុ$M_2$។

តារាង៣.១. សមាមាត្រចំនួនប្រាក់រៀល នៅក្នុងរូបិយវត្ថុ $M_2$ ឆ្នាំ២០២១

| | មករា | កុម្ភៈ | មីនា | មេសា | ឧសភា | មិថុនា | កក្កដា | សីហា | កញ្ញា | តុលា | វិច្ឆិកា | ធ្នូ |
|---|---|---|---|---|---|---|---|---|---|---|---|---|
| ប្រាក់រៀលសរុបនៅក្នុងនិងក្រៅស្ថាប័នទទួលប្រាក់បញ្ញើ | ១៦,៤% | ១៦,៧% | ១៦,៧% | ១៧,៤% | ១៧,៤% | ១៧,៣% | ១៧,៦% | ១៧,៧% | ១៧,៤% | | | |
| រូបិយបណ្ណបរទេសនៅក្នុងធនាគារ | ៨៣,៦% | ៨៣,៣% | ៨៣,៣% | ៨២,៦% | ៨២,៦% | ៨២,៧% | ៨២,៤% | ៨២,៣% | ៨២,៦% | | | |

## ក្រាហ្វ៣.២.បម្រែបម្រួលរូបិយវត្ថុក្នុងត្រីមាសទី៣ ឆ្នាំ២០២១

(ក្នុងរង់ក្រចកជាបម្រែបម្រួលធៀបនឹងត្រីមាសដូចគ្នាឆ្នាំមុន)



តារាង៣.៣.ការផ្តល់ឥណទាននិងអត្រាការប្រាក់ប្រចាំឆ្នាំ

| ផ្តល់ដោយ | ត្រីមាសទី៣ ២០២១ | ត្រីមាសទី២ ២០២១ | ត្រីមាសទី៣ ២០២០ |
|---|---|---|---|
| ឥណទានផ្តល់ដោយធនាគារពាណិជ្ជ(ប៊ីលានរៀល)<br>ក្នុងនោះ ជារៀល | ១៥១ ៧០៧,០<br>១៦ ៧២០,១ | ១៤៣ ៩៧៧,២<br>១៦ ០០៣,៨ | ១១៩ ៥៣២,២<br>១៣ ២៣៤,៥ |
| ឥណទានផ្តល់ដោយគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ(ប៊ីលានរៀល) | ៣៣ ៤១៧,៨ | ៣០ ៧៩០,៣ | ៣០ ៩១៦,១ |
| បញ្ញើជារៀលនៅធនាគារពាណិជ្ជ | ៤,៣% | ៤,៥% | ៤,៧% |
| បញ្ញើជាដុល្លារនៅធនាគារពាណិជ្ជ | ៣,៥% | ៣,៥% | ៣,២% |
| កម្ចីជារៀលនៅធនាគារពាណិជ្ជ | ១០,៦% | ១០,៤% | ១០,៩% |
| កម្ចីជាដុល្លារនៅធនាគារពាណិជ្ជ | ៨,៦% | ៨,៣% | ៨,០% |
| កម្ចីជារៀលនៅហត្ថាកសិករ | ១៧,៩% | ១៧,៦% | ១៨,០% |
| កម្ចីជារៀលនៅអម្រឹត | ១៨,០% | ១៨,០% | ១៧,៨% |
| កម្ចីជារៀលនៅប្រាសាក់ | ១៥,៨% | ១៦,៣% | ១៦,០% |

## ៤. ស្ថានភាពកសិកម្ម ឧស្សាហកម្ម ថាមពល សេវាកម្ម និងវប្បធម៌ (តារាង៤)

➡ក្នុងត្រីមាសទី៣ ឆ្នាំ២០២១ ស្ថានភាពផលិតកម្មមានលក្ខណៈដូចខាងក្រោម:

➤**កសិកម្ម**:

✓នេសាទសម្រេចបាន ១០៩,២ ពាន់តោនថយចុះ៣៣,០% ធៀបនឹងត្រីមាសមុននិងថយចុះ៦២,៧%ធៀបនឹងត្រីមាសដូចគ្នាឆ្នាំមុន។

➤**រ៉ែ និងថាមពល**:

✓អគ្គិសនីសរុបផ្គត់ផ្គង់ដោយអគ្គិសនីកម្ពុជាមានចំនួន ៣ ៣៤៣,២ GWh មានការកើនឡើង៣,៦% ធៀបនឹងត្រីមាសមុន និង កើនឡើង១១,២% ធៀបនឹងត្រីមាសដូចគ្នាឆ្នាំមុន។ ក្នុងនោះ៖

- អគ្គីសនីផ្គត់ផ្គង់ដោយវារីអគ្គិសនីមានចំនួន ២ ០៦៩,៣ GWh ( ស្មើ៦១,៩%នៃអគ្គិសនីសរុបផ្គត់ផ្គង់ដោយអគ្គិសនីកម្ពុជា) មានការកើនឡើង១១០,៥% ធៀបនឹងត្រីមាសមុននិង កើនឡើង២៤,០% ធៀបនឹងត្រីមាសដូចគ្នាឆ្នាំមុន។
- អគ្គីសនីផ្គត់ផ្គង់ដោយធ្យូងថ្មមានចំនួន ៤៤៦,២ GWh ( ស្មើ១៣,៣%នៃអគ្គិសនីសរុបផ្គត់ផ្គង់ដោយអគ្គិសនីកម្ពុជា) មានការថយចុះ៥៩,៣% ធៀបនឹងត្រីមាសមុននិង ថយចុះ៣៧,៨% ធៀបនឹងត្រីមាសដូចគ្នាឆ្នាំមុន។
- អគ្គីសនីផ្គត់ផ្គង់ដោយថាមពលពន្លឺព្រះអាទិត្យ (Solar) មានចំនួន ១៥៣,១ GWh ( ស្មើ៤,៦%នៃអគ្គិសនីសរុបផ្គត់ផ្គង់ដោយអគ្គិសនីកម្ពុជា) មានការថយចុះ៤,៤% ធៀបនឹងត្រីមាសមុនប៉ុន្តែ កើនឡើង១១៥,៤% ធៀបនឹងត្រីមាសដូចគ្នាឆ្នាំមុន។
- អគ្គិសនីដែលនាំចូលពីប្រទេសជិតខាងដោយ EDCមានចំនួន ៦៦៣,១ GWh ( ស្មើ១៩,៨%នៃអគ្គិសនីសរុបផ្គត់ផ្គង់ដោយអគ្គិសនីកម្ពុជា) មានការថយចុះ២២,១% ធៀបនឹងត្រីមាសមុនប៉ុន្តែ កើនឡើង២៥,៤% ធៀបនឹងត្រីមាសដូចគ្នាឆ្នាំមុន។
- និងអគ្គិសនីផ្គត់ផ្គង់ដោយប្រភពផ្សេងទៀតមានចំនួន ១១,៥ GWh ( ស្មើ០,៣%នៃអគ្គិសនីសរុបផ្គត់ផ្គង់ដោយអគ្គិសនីកម្ពុជា) មានការថយចុះ៩១,៥% ធៀបនឹងត្រីមាសមុននិង ថយចុះ៤៤,១% ធៀបនឹងខែដូចគ្នាឆ្នាំមុន។

### ➢ឧស្សាហកម្ម:

តារាង៤.១. ការចុះបញ្ជីរោងចក្រ និងឧស្សាហកម្មធុនតូច និងសិប្បកម្ម នៅក្រសួងឧស្សាហកម្ម

| ប្រភេទ | ចំនួន –ត្រីមាសទី៣ ២០២១ | ចំនួន–ត្រីមាសទី២ ២០២១ | ចំនួន–ត្រីមាសទី៣ ២០២០ |
|---|---|---|---|
| ▪រោងចក្រថ្មីដែលបានចុះបញ្ជី | ៤៦ | ៣០ | ៧៧ |
| ▪ ចំនួនរោងចក្រសរុបដែលមានក្នុងបញ្ជី | ១ ៨៤៣ | ១ ៨១៦ | ១ ៨០១ |
| ▪ ឧស្សាហកម្មធុនតូចនិងសិប្បកម្ម (បើកថ្មី) | ៣៣៩ | ១៣៧ | |
| ▪ឧស្សាហកម្មធុនតូច និងសិប្បកម្ម (បន្ត) | ៣៦៣ | ១១៨ | |

### ➢សំណង់ (ការអនុញ្ញាត):

✓សំណង់អនុញ្ញាតឲ្យសាងសង់មានចំនួន ៤ ៦៧៣,៥ ពាន់ម² មានការកើនឡើង១០៨,៥% ធៀបនឹងត្រីមាសមុននិងកើនឡើង៨,៣% ធៀបនឹងត្រីមាសដូចគ្នាឆ្នាំមុន។ បើគិតជាសាច់ប្រាក់ស្មើនឹង ១ ៨៨៥,៦ លានដុល្លារមានការកើនឡើង១១៨,៦% ធៀបនឹងត្រីមាសមុនប៉ុន្តែ ថយចុះ៦,៩% បើធៀបនឹងត្រីមាសដូចគ្នាឆ្នាំមុន។ ក្នុងនោះប្រភេទសំណង់ចម្បងៗមាន:

តារាង៤.២. សំណង់អនុញ្ញាតតាមប្រភេទផ្សេងៗ

| ប្រភេទ | ពាន់ម² – ត្រីមាសទី៣ ២០២១ | ពាន់ម² –ត្រីមាសទី២ ២០២១ | ពាន់ម² –ត្រីមាសទី៣ ២០២០ |
|---|---|---|---|
| ▪ លំនៅឋាន | ២ ៨៦៥,៧ | ១ ៥២៣,៥ | ១ ៦៦៩,៤ |
| ▪ ឧស្សាហកម្ម | ៩៣៣,៤ | ៥២៥,៨ | ៦៥៦,៥ |
| ▪ពាណិជ្ជកម្ម | ៥០៨,៣ | ៨៥,៦ | ១ ៦៤៣,៧ |
| ▪ ទេសចរណ៍ | ២៦៩,៤ | ៥៧,៣ | ១២៨,១ |
| ▪ផ្សេងៗ | ០,០ | ៩,០ | ០,០ |
| អនុញ្ញាតសរុប | ៤ ៦៧៣,៥ | ២ ២៤១,៤ | ៤ ៣១៤,៣ |

✓ដូច្នេះសំណង់អនុញ្ញាតដែលពេញនិយមនាត្រីមាសនេះគឺលំនៅដ្ឋាន ៦១,៣% និងឧស្សាហកម្ម២០,០%នៃផ្ទៃក្រឡាសរុប។

### ➢សេវាកម្ម

តារាង៤.៣.ការចុះបញ្ជីនិងលុបចេញពីបញ្ជី នៅក្រសួងពាណិជ្ជកម្ម

| ប្រភេទ | ចំនួន –ត្រីមាសទី៣ ២០២១ | ចំនួន–ត្រីមាសទី២ ២០២១ | ចំនួន–ត្រីមាសទី៣ ២០២០ |
|---|---|---|---|
| ក្រុមហ៊ុនដែលបានចុះបញ្ជីពាណិជ្ជកម្ម | ១ ២៩២ | ៩២២ | ១ ០៩៤ |
| ក្រុមហ៊ុនត្រូវបានលុបចេញពីបញ្ជីពាណិជ្ជកម្ម | ១៦២ | ១២៧ | ១២៤ |
| សហគ្រាសដែលបានចុះបញ្ជីពន្ធដារ | ១ ៥៩៣ | ១ ២៦៧ | ១ ៨២១ |

### ➢ការងារ

តារាង៤.៤. ការស្វែងរកការងារនិងទទួលបានការងារ

| ប្រភេទ | នាក់–ត្រីមាសទី៣ ២០២១ | នាក់–ត្រីមាសទី២ ២០២១ | នាក់–ត្រីមាសទី៣-២០២០ |
|---|---|---|---|
| អ្នកចុះឈ្មោះស្វែងរកការងារ (ទីភ្នាក់ងារជាតិមុខរបបនិងការងារ) | ៧៧៣ | ៦១៣ | ៦ ៤៨១ |
| អ្នកទទួលបានការងារធ្វើតាមរយៈ ក្រសួងការងារ និង បណ្តុះបណ្តាលវិជ្ជាជីវៈ និងទីភ្នាក់ងារជ្រើសរើសឯកជន | ៣៦ ៧៨១ | ១០ ១៨១ | ៥៦ ៧៥៣ |
| អ្នកទទួលបានការងារក្នុងប្រទេស | ៣៦ ៤៤៨ | ៩ ០០៨ | ៥៦ ៧០៨ |
| អ្នកទទួលបានការងារក្រៅប្រទេស | ៣៣៣ | ១ ១៧៣ | ៤៥ |

### ➢វិនិយោគ

តារាង៤.៥.គម្រោងវិនិយោគអនុញ្ញាតដោយ ក.អ.ក. (ថ្មីនិងពង្រីក)

| ប្រភេទ | ត្រីមាសទី៣ ២០២១ | ត្រីមាសទី២ ២០២១ | ត្រីមាសទី៣ ២០២០ |
|---|---|---|---|
| អនុញ្ញាតសរុប (លានដុល្លារ) | ៣៨៩,១ | ៤២៧,៣ | ៣ ៧៨៨,២ |
| វិស័យកសិកម្មនិងកសិឧស្សាហកម្ម | ២៧,៥ | ៤៦,៨ | ៣៤,២ |
| វិស័យឧស្សាហកម្ម (ក្នុងវង់ក្រចកជាតួលេខនៃតំបន់សេដ្ឋកិច្ចពិសេស) | ២៨៩,៥ (៨២,៧) | ១៩៣,០ (៤១,៣) | ១៩៩,០ (៣៣,៨) |
| វិស័យទេសចរណ៍ | ០,០ | ១២៧,៨ | ៣ ៥១៥,១ |
| វិស័យហេដ្ឋារចនាសម្ព័ន្ធនិងផ្សេងៗ | ៧២,១ | ៥៩,៧ | ៣៩,៩ |
| ចំនួនគម្រោង ថ្មីនិងពង្រីក (ចំនួន) | ៤៧ | ៣៨ | ៣៨ |
| បង្កើតការងារ (ពាន់នាក់) | ៣៥,៥ | ២០,៦ | ២៦,៩ |

➢**ទំនិញឆ្លងកាត់កំពង់ផែ**(សរុប២កំពង់ផែ) មានចំនួន ២ ២៩១,៣ ពាន់តោន មានការថយចុះ១៤,៧% ធៀបនឹងត្រីមាសមុននិងមានការថយចុះ៧,៤% ធៀបនឹងត្រីមាសដូចគ្នាឆ្នាំមុន។ក្នុងនោះ:

តារាង៤.៦.ទំនិញឆ្លងកាត់កំពង់ផែផ្សេងៗ (ក្នុងវង់ក្រចក: បម្រែបម្រួលធៀបនឹងត្រីមាសដូចគ្នាឆ្នាំមុន)

| | |
|---|---|
| ▪ កំពង់ផែភ្នំពេញ:-៣៦,៨% (-៤៣,៥%) | ▪ កំពង់ផែកំពង់សោម:-៣,៦% (+១៧,២%) |

## ➤ការចុះបញ្ជី និងចរាចរណ៍

តារាង៤.៧.ការចុះបញ្ជីម៉ូតូ រថយន្ត និងគ្រោះថ្នាក់ចរាចរណ៍

| ប្រភេទ | ចំនួន –ត្រីមាសទី៣ ២០២១ | ចំនួន–ត្រីមាសទី២ ២០២១ | ចំនួន–ត្រីមាសទី៣ ២០២០ |
|---|---|---|---|
| ចំនួនម៉ូតូបានចុះបញ្ជី (ពាន់គ្រឿង) | ៩៦,៦ | ៦៨,៦ | ៧០,៣ |
| ចំនួនរថយន្តគ្រប់ប្រភេទបានចុះបញ្ជី(ពាន់គ្រឿង) | ១៨,៥ | ១៣,៨ | ១៩,៩ |
| ចំនួនគ្រោះថ្នាក់ចរាចរណ៍ (លើក) | ៦២៧ | ៥០៨ | ៨១១ |

## ➤ប្រៃសណីយ៍និងទូរគមនាគមន៍

| ប្រភេទ | ចំនួន | %Δ ធៀបនឹងត្រីមាសមុន | %Δធៀបនឹងត្រីមាសដូចគ្នាឆ្នាំមុន |
|---|---|---|---|
| បញ្ញើក្នុងប្រទេស(ពាន់កញ្ចប់) | ៣៦,៦ | +៣៣,៦% | +៥១,៦% |
| ក្នុងនោះទទួល | ៩,០ | +១៣,៣% | +២៥,៨% |
| បញ្ញើក្រៅប្រទេស(ពាន់កញ្ចប់) | ៩៨,៨ | +៤០,៦% | +៩៧,២% |
| ក្នុងនោះទទួល | ៨៦,០ | +៥១,០% | +១២៣,១% |
| សន្ទនាទូរសព្ទក្នុងប្រទេស(ពាន់នាទី) | ៣ ១៥២,៦ | +០,៧% | +១១,៦% |
| ក្នុងនោះហៅចូល | ១ ៣៧៩,៦ | -៤,៥% | +១៦,១% |
| សន្ទនាទូរសព្ទក្រៅប្រទេស(ពាន់នាទី) | ៥ ២០៨,៦ | -២៧,៦% | -៤១,១% |
| ក្នុងនោះហៅចូល | ៥ ១១៥,០ | -២៨,៥% | -៤០,៩% |

## ➤ ការធ្វើដំណើរតាមផ្លូវអាកាស វប្បធម៌ និងទេសចរណ៍

តារាង៤.៨.អ្នកដំណើរតាមផ្លូវអាកាស វប្បធម៌ និងទេសចរណ៍

| ប្រភេទ | ចំនួន(ពាន់នាក់) | %Δ ធៀបនឹង ត្រីមាសមុន | %Δធៀបនឹងត្រីមាសដូចគ្នាឆ្នាំមុន |
|---|---|---|---|
| ភ្ញៀវអន្តរជាតិចូលទស្សនាសារមន្ទីរជាតិ | ០,០ | - | - |
| ភ្ញៀវទេសចរបរទេសទិញប័ណ្ណទស្សនាអង្គរ | ០,៨ | -១,១% | -៩០,០% |
| ភ្ញៀវទេសចរចូលទស្សនា រមណីយដ្ឋានព្រះវិហារ | ១,៨ | -៥២,១% | -៩៦,៨% |
| អ្នកដំណើរតាមផ្លូវអាកាស (ក្នុងស្រុក) | ០,៦ | -៨៧,៥% | -៧៦,៥% |
| អ្នកដំណើរតាមផ្លូវអាកាស (អន្តរជាតិ) | ៤៣,៩ | -១៧,៩% | -៥៦,៤% |
| ចំនួនទេសចរជាតិចេញក្រៅប្រទេស | ៦,៥ | +២៩,៧% | +២,៩% |
| ចំនួនទេសចរអន្តរជាតិមកព្រះរាជាណាចក្រកម្ពុជា | ២៩,១ | -៨,០% | -៥៥,១% |
| ✓ តាមផ្លូវអាកាស | ១៦,៨ | +៣២,១% | -៥៣,៧% |
| ✓ តាមផ្លូវគោក និងទឹក | ១២,៣ | -៣៥,០% | -៥៦,៨% |

# ៥. ស្ថានភាពជញ្ជីងពាណិជ្ជកម្ម(តារាង៥)

➡ពីប្រភពអគ្គនាយកដ្ឋានគយនិងរដ្ឋាករ **ការនាំចូល**នាត្រីមាសទី៣ ឆ្នាំ២០២១ មានចំនួន ២៧ ៦២៧,៣ ប៊ីលានរៀល (ស្មើនឹង ៦ ៩០៦,៨ លានដុល្លារ ស.រ.អា.) កើនឡើង៨,០%ធៀបនឹងត្រីមាសមុននិង កើនឡើង៥៤,១% ធៀបនឹងត្រីមាសដូចគ្នាឆ្នាំមុនក្នុងនោះ៖

តារាង៥.១.បម្រែបម្រួលនៃការនាំចូលមុខទំនិញមួយចំនួន

| ទំនិញ | %∆ធៀបនឹងត្រីមាសមុន | %∆ធៀបនឹងត្រីមាសដូចគ្នាឆ្នាំមុន | ទំនិញ | %∆ធៀបនឹងត្រីមាសមុន | %∆ធៀបនឹងត្រីមាសដូចគ្នាឆ្នាំមុន |
|---|---|---|---|---|---|
| ប្រេងសាំង | +១១,៧% | -១៣,៣% | រថយន្តសរុប (ប៊ី.ល.រ) | -៧,៩% | +១៥,៦% |
| ប្រេងម៉ាស៊ូត | +២៤,៩% | -៨,២% | រថយន្តសរុប (គ្រឿង) | -៧,៥% | +២,១% |
| ឧស្ម័ន | -៥,៧% | -២,៥% | ត្រាក់ទ័រនិងគោយន្ត | -១១,៩% | +៨២,៦% |
| អគ្គិសនីនាំចូលដោយ EDC | -២២,១% | +២៥,៤% | ស្រូវសាលី | -៣២,២% | +០,៤% |
| ដែកសំណង់ | -៩,៨% | -៦៣,៦% | អង្ករ | -៥៧,៨% | -៨០,៤% |
| ស៊ីម៉ង់ត៍ | -៥១,៧% | -៤៣,៨% | ផ្លែឈើនិងបន្លែ | +៥,៩% | -០,៤% |
| | | | ថ្នាំកសិកម្ម | -២៣,៣% | -៨០,៤% |
| | | | នាំចូលក្នុងក្របខណ្ឌច្បាប់វិនិយោគ | -៣,៧% | +៣២,៥% |

➡ **ការនាំចេញ** ត្រីមាសទី៣ ឆ្នាំ២០២១ មានចំនួន **២១ ៩១៤,៧** ប៊ីលានរៀល ស្មើនឹង **៥ ៤៧៨,៧** លានដុល្លារ ស.រ.អា. (**៧៩,៣**% នៃការនាំចូល)កើនឡើង៤៧,៤% ធៀបនឹងត្រីមាសមុនប៉ុន្តែ ថយចុះ៤,៥% ធៀបនឹងត្រីមាសដូចគ្នាឆ្នាំមុន។

តារាង៥.២.បម្រែបម្រួលនៃការនាំចេញមុខទំនិញមួយចំនួនឲ្យ

| *ទំនិញ* | *%∆ធៀបនឹងត្រីមាសមុន* | *%∆ធៀបនឹងត្រីមាសដូចគ្នាឆ្នាំមុន* | *ទំនិញ* | *%∆ធៀបនឹងត្រីមាសមុន* | *%∆ធៀបនឹងត្រីមាសដូចគ្នាឆ្នាំមុន* |
|---|---|---|---|---|---|
| ផលិតផលឈើកែឆ្នៃ | +១១,៩% | -១៥,៩% | ផលិតផលនេសាទ | -៥០,៨% | -៧,៥% |
| វាយនភណ្ឌនិងស្បែកជើង | +៧០,៣% | +២៦,៩% | កៅស៊ូ | +៧៤,៤% | +៣,៧% |
| អង្ករ | -៤,៤% | +៤៦,៤% | | | |

## តារាងទី ១ : សន្ទស្សន៍ថ្លៃទំនិញប្រើប្រាស់ [1)]

| ល.រ | សូចនាករ | មេគុណ | 2017 | 2018 | 2019 | 2020 | 2021 | 2019 | | | | 2020 | | | | 2021 | | | %Δធៀបនឹងត្រីមាស | |
|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|
| | | | ∅ | ∅ | ∅ | ∅ | ០៩ខែ | ត្រីមាស១ | ត្រីមាស២ | ត្រីមាស៣ | ត្រីមាស៤ | ត្រីមាស១ | ត្រីមាស២ | ត្រីមាស៣ | ត្រីមាស៤ | ត្រីមាស១ | ត្រីមាស២ | ត្រីមាស៣ | មុន | ដូចគ្នាឆ្នាំមុន |
| 0 | គ្រប់មុខទំនិញ (២៥៩ មុខ) | 100 | 169.9 | 174.0 | 177.4 | 182.6 | 186.8 | 175.7 | 177.0 | 178.1 | 178.9 | 181.0 | 181.4 | 183.1 | 185.0 | 184.8 | 186.6 | 189.0 | 1.3 | 3.2 |
| | អត្រាអតិផរណាធៀបនឹងគ្រាមុន% | _ | 2.9 | 2.5 | 1.9 | 2.9 | 2.3 | 0.2 | 0.8 | 0.6 | 0.4 | 1.2 | 0.3 | 0.9 | 1.1 | -0.1 | 0.9 | 1.3 | _ | _ |
| ១ | ម្ហូបអាហារ និងភេសជ្ជៈមិនមែនជាតិស្រវឹង | 45 | 206.7 | 211.8 | 216.2 | 226.2 | 231.3 | 213.7 | 215.3 | 217.4 | 218.4 | 221.7 | 225.8 | 227.0 | 230.4 | 228.6 | 231.2 | 234.0 | 1.2 | 3.1 |
| | ០១.១. ម្ហូបអាហារ | 43 | 209.0 | 214.2 | 218.7 | 229.1 | 234.3 | 216.1 | 217.9 | 220.0 | 221.0 | 224.4 | 228.7 | 230.0 | 233.4 | 231.5 | 234.3 | 237.1 | 1.2 | 3.1 |
| | ០១.១.១.១ អង្ករ | 6.2 | 213.9 | 219.1 | 226.3 | 233.5 | 235.8 | 222.8 | 225.0 | 228.3 | 229.2 | 231.8 | 233.2 | 234.4 | 234.6 | 234.7 | 236.4 | 236.3 | 0.0 | 0.8 |
| | ០១.១.២.១ សាច់ជ្រូក | 5.6 | 209.7 | 212.8 | 209.7 | 226.7 | 237.5 | 213.4 | 215.9 | 203.9 | 205.6 | 217.9 | 223.9 | 229.9 | 235.3 | 234.7 | 237.6 | 240.4 | 1.2 | 4.6 |
| | ០១.១.២.២ សាច់គោស្រស់ | 2.2 | 239.2 | 245.7 | 250.4 | 259.2 | 263.4 | 248.2 | 248.6 | 251.5 | 253.2 | 254.8 | 258.2 | 261.3 | 262.5 | 261.4 | 263.2 | 265.6 | 0.9 | 1.7 |
| | ០១.១.២.៤ សាច់មាន់ស្រស់ | 1.3 | 208.7 | 212.2 | 219.0 | 223.5 | 225.3 | 217.1 | 217.7 | 219.6 | 221.7 | 223.3 | 223.4 | 223.4 | 224.1 | 223.6 | 225.9 | 226.5 | 0.3 | 1.4 |
| | ០១.១.៣.១ ត្រីស្រស់ | 7.4 | 207.2 | 215.4 | 222.6 | 241.3 | 250.3 | 215.9 | 217.4 | 227.3 | 229.7 | 232.5 | 240.4 | 243.6 | 248.6 | 247.1 | 250.3 | 253.4 | 1.2 | 4.0 |
| | ០១.១.៦ ផ្លែឈើ | 4.7 | 212.7 | 217.5 | 222.6 | 231.8 | 234.2 | 218.4 | 220.6 | 225.6 | 225.8 | 226.8 | 233.3 | 231.1 | 236.0 | 230.9 | 233.5 | 238.3 | 2.1 | 3.1 |
| | ០១.១.៧ បន្លែ | 4.8 | 220.2 | 226.1 | 231.2 | 238.6 | 245.2 | 227.7 | 230.8 | 233.3 | 233.0 | 235.9 | 238.2 | 236.7 | 243.6 | 240.7 | 244.8 | 249.9 | 2.1 | 5.6 |
| ២ | ភេសជ្ជៈមានជាតិស្រវឹង និងថ្នាំជក់ | 1.6 | 159.7 | 162.7 | 171.4 | 175.3 | 177.0 | 170.3 | 170.7 | 171.9 | 172.9 | 174.3 | 174.4 | 174.6 | 177.7 | 177.0 | 177.0 | 177.0 | 0.0 | 1.4 |
| ៣ | សម្លៀកបំពាក់ និងស្បែកជើង | 3.0 | 144.7 | 147.7 | 151.4 | 155.8 | 161.6 | 150.5 | 150.8 | 151.9 | 152.5 | 153.7 | 154.8 | 156.2 | 158.7 | 159.1 | 160.5 | 165.2 | 2.9 | 5.7 |
| ៤ | ផ្ទះសំបែង ទឹក អគ្គិសនី ឧស្ម័ន និងឥន្ធនៈផ្សេងទៀត | 17 | 124.4 | 126.1 | 127.7 | 129.1 | 131.7 | 127.1 | 127.8 | 127.9 | 127.9 | 128.5 | 128.3 | 129.4 | 130.0 | 130.7 | 131.3 | 133.0 | 1.3 | 2.8 |
| | ០៤.៥.២ ឧស្ម័ន | 2.7 | 108.7 | 116.5 | 123.3 | 122.8 | 130.7 | 120.4 | 125.2 | 124.0 | 123.5 | 124.5 | 119.7 | 123.6 | 123.3 | 127.7 | 130.9 | 133.7 | 2.2 | 8.2 |
| ៥ | គ្រឿងសង្ហារឹម និងសម្ភារៈប្រើប្រាស់ | 2.7 | 150.1 | 150.7 | 152.7 | 153.6 | 154.5 | 152.8 | 152.3 | 152.6 | 152.9 | 153.4 | 154.1 | 153.2 | 153.8 | 153.8 | 154.3 | 155.4 | 0.8 | 1.5 |
| ៦ | សុខាភិបាល | 5.1 | 133.3 | 135.4 | 137.1 | 137.3 | 138.3 | 137.1 | 137.0 | 136.8 | 137.2 | 137.4 | 137.2 | 137.1 | 137.4 | 137.0 | 138.3 | 139.7 | 1.0 | 1.9 |
| ៧ | ការដឹកជញ្ជូន | 12 | 113.2 | 116.5 | 113.8 | 108.7 | 116.7 | 111.6 | 115.3 | 113.9 | 114.5 | 114.5 | 102.8 | 108.6 | 108.9 | 113.9 | 116.3 | 119.9 | 3.0 | 10.3 |
| | ០៧.២.២.១ ប្រេងសាំង | 5.0 | 91.1 | 97.0 | 88.6 | 75.4 | 91.8 | 83.6 | 91.7 | 89.0 | 89.9 | 89.6 | 61.9 | 75.2 | 75.1 | 85.0 | 90.8 | 99.6 | 9.7 | 32.4 |
| | ០៧.២.២.២ ប្រេងម៉ាស៊ូត | 0.1 | 106.7 | 113.0 | 108.5 | 87.0 | 104.0 | 104.6 | 110.7 | 108.8 | 109.9 | 109.4 | 72.5 | 83.2 | 83.1 | 97.0 | 103.5 | 111.3 | 7.5 | 33.8 |
| ៨ | ទូរគមនាគមន៍ | 1.1 | 68.1 | 67.6 | 67.1 | 66.7 | 66.5 | 67.5 | 67.2 | 67.0 | 67.0 | 67.0 | 66.7 | 66.6 | 66.5 | 66.6 | 66.4 | 66.5 | 0.1 | -0.2 |
| ៩ | ការកម្សាន្ត និងវប្បធម៌ | 2.9 | 118.7 | 118.4 | 119.3 | 120.3 | 120.6 | 118.9 | 118.9 | 119.8 | 119.6 | 120.0 | 119.8 | 120.4 | 120.8 | 120.7 | 120.4 | 120.9 | 0.4 | 0.4 |
| ១០ | ការសិក្សា | 1.2 | 159.8 | 159.6 | 160.4 | 165.0 | 165.1 | 159.5 | 159.5 | 159.9 | 162.7 | 164.1 | 164.9 | 165.5 | 165.5 | 165.3 | 165.1 | 164.9 | -0.1 | -0.3 |
| ១១ | ភោជនីយដ្ឋាន | 5.9 | 254.8 | 269.8 | 286.6 | 297.8 | 298.3 | 283.5 | 284.3 | 288.1 | 290.6 | 296.2 | 296.1 | 298.6 | 300.3 | 297.0 | 297.2 | 300.8 | 1.2 | 0.8 |
| ១២ | ទំនិញ និងសេវាកម្មផ្សេងៗ | 2.3 | 140.9 | 144.8 | 147.3 | 153.48 | 160.6 | 145.6 | 146.5 | 148.3 | 148.9 | 150.6 | 152.6 | 154.6 | 156.1 | 159.7 | 160.2 | 162.0 | 1.1 | 4.8 |

**សម្គាល់** : តួលេខប្រើប្រាស់ក្នុងតារាងទាំងអស់ ជាតួលេខប្រព័ន្ធអង់គ្លេស។

[1)] សន្ទស្សន៍ថ្លៃទំនិញប្រើប្រាស់នៅរាជធានីភ្នំពេញ (គ្រាគោល: តុលា-ធ្នូ ២០០៦=១០០)

**ប្រភពទិន្នន័យ** : ០-១២ វិទ្យាស្ថានជាតិស្ថិតិនៃក្រសួងផែនការ ១៣, ១៤, ១៥, ១៦,១៧ ធនាគារជាតិនៃកម្ពុជា

| ល.រ | សូចនាករ | 2018 | 2019 | 2020 | 2021 | 2020 | | | | 2021 | | | %Δធៀបនឹងត្រីមាស | |
|---|---|---|---|---|---|---|---|---|---|---|---|---|---|---|
| | | | | | ខែ៩ | ត្រីមាស១ | ត្រីមាស២ | ត្រីមាស៣ | ត្រីមាស៤ | ត្រីមាស១ | ត្រីមាស២ | ត្រីមាស៣ | មុន | ដូចគ្នាឆ្នាំមុន |
| ១៣ | អត្រាប្តូរប្រាក់ផ្លូវការនាចុងខែ (៛/ដុល្លារ) | 4,000 | 4,075 | 4,045 | 4,045 | 4,070 | 4,093 | 4,100 | 4,045 | 4,045 | 4,075 | 4,079 | 0.1 | -0.5 |
| ១៤ | អត្រាប្តូរប្រាក់ផ្លូវការនាចុងខែ (៛/បាត) | 128 | 136 | 135 | 129 | 125 | 133 | 130 | 135 | 129 | 127 | 120 | -5.5 | -7.7 |
| ១៥ | អត្រាប្តូរប្រាក់ផ្លូវការនាចុងខែ (៛/ដុង) | 0.175 | 0.176 | 0.175 | 0.175 | 0.172 | 0.177 | 0.177 | 0.175 | 0.175 | 0.177 | 0.179 | 1.1 | 1.1 |
| ១៦ | អត្រាប្តូរប្រាក់ផ្លូវការនាចុងខែ(៛/យ៉ន់) | 584 | 583 | 619 | 616 | 573 | 578 | 602 | 619 | 616 | 630 | 630 | 0.0 | 4.7 |
| ១៧ | អត្រាប្តូរប្រាក់ផ្លូវការនាចុងខែ(ដុង/ដុល្លារ) | 22,805 | 23,171 | 23,067 | 23,069 | 23,633 | 23,175 | 23,163 | 23,067 | 23,069 | 22,997 | 22,735 | -1.14 | -1.8 |
| ១៨ | អត្រាប្តូរប្រាក់ផ្លូវការនាចុងខែ(បាត/ដុល្លារ) | 31.2 | 30.0 | 30.0 | 31.3 | 32.7 | 30.9 | 31.6 | 30.0 | 31.3 | 32.1 | 33.9 | 5.7 | 7.3 |
| ១៩ | អត្រាប្តូរប្រាក់ផ្លូវការនាចុងខែ(យ៉ន់/ដុល្លារ) | 6.88 | 7.0 | 6.5 | 6.6 | 7.1 | 7.1 | 6.8 | 6.5 | 6.6 | 6.5 | 6.5 | 0.1 | -5.1 |

រូប១ (ក) បំរែបំរួលសន្ទស្សន៍ថ្លៃនៃ ក្រុមម្ហូបអាហារ និងអត្រាប្តូរប្រាក់




រូប១ (ខ) សន្ទស្សន៍ថ្លៃទំនិញគ្រប់មុខ និងក្រុមទំនិញធំៗ



## ឧបសម្ព័ន្ធ : ថ្លៃមុខទំនិញសំខាន់ៗមួយចំនួន (រៀល)

| ល.រ | មុខទំនិញ | 2018 | 2019 | 2020 | 2021 | 2020 | | | | 2021 | | | | | | | | | Δ ថ្លៃ | |
|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|
| | | ∅ | ∅ | ∅ | ∅៣ខែ | កញ្ញា | តុលា | វិច្ឆិកា | ធ្នូ | មករា | កុម្ភៈ | មីនា | មេសា | ឧសភា | មិថុនា | កក្កដា | សីហា | កញ្ញា | ១ខែ | ១២ខែ |
| ១ | អង្ករលេខ២ (៛/១គ.ក្រ) | 2,693 | 2,843 | 2,973 | 2,993 | 3,003 | 2,978 | 2,993 | 2,990 | 2,993 | 2,978 | 2,996.0 | 2,992.0 | 3,002.0 | 3,020.0 | 2,990.0 | 2,979.0 | 2,987 | 0.3 | -0.5 |
| ២ | សាច់គោស្រស់លេខ១ (៛/១គ.ក្រ) | 42,994 | 43,805 | 45,360 | 46,111 | 45,830 | 45,940 | 45,965 | 45,930 | 46,015 | 45,440 | 45,805.0 | 45,830.0 | 46,275.0 | 46,135.0 | 46,410.0 | 46,595.0 | 46,495 | -0.21 | 1.4 |
| ៣ | សាច់ជ្រូកសុទ្ធ (៛/១គ.ក្រ) | 22,766 | 22,265 | 24,229 | 25,461 | 24,775 | 25,165 | 25,190 | 25,205 | 25,250 | 24,795 | 25,205.0 | 25,210.0 | 25,710.0 | 25,480.0 | 25,775.0 | 25,890.0 | 25,835 | -0.21 | 4.1 |
| ៤ | សាច់មាន់ស្រស់ (៛/១គ.ក្រ) | 25,266 | 26,075 | 26,614 | 26,826 | 26,585 | 26,735 | 26,715 | 26,610 | 26,780 | 26,345 | 26,735.0 | 26,700.0 | 27,180.0 | 26,810.0 | 26,950.0 | 27,010.0 | 26,925 | -0.31 | 1.3 |
| ៥ | ត្រីរ៉ស់ធំ (៛/១គ.ក្រ) | 20,163 | 21,741 | 24,989 | 26,239 | 25,350 | 25,690 | 26,895 | 26,895 | 26,905 | 25,335 | 25,945.0 | 25,905.0 | 26,385.0 | 26,180.0 | 26,460.0 | 26,575.0 | 26,465 | -0.41 | 4.2 |
| ៦ | ប្រេងសាំង-ធម្មតា (៛/១លីត) | 3,948 | 3,604 | 3,072 | 3,733 | 3,063 | 3,063 | 3,053 | 3,058 | 3,358 | 3,500 | 3,513.0 | 3,537.0 | 3,639.0 | 3,900.0 | 4,100.0 | 4,000.0 | 4,050 | 1.25 | 24.4 |
| ៧ | ប្រេងម៉ាស៊ូត (៛/១លីត) | 3,689 | 3,545 | 2,841 | 3,394 | 2,716 | 2,716 | 2,705 | 2,718 | 3,061 | 3,218 | 3,226.0 | 3,245.0 | 3,345.0 | 3,550.0 | 3,650.0 | 3,600.0 | 3,650 | 1.39 | 25.6 |
| ៨ | ឧស្ម័ន (៛/ធុង១៥គ.ក្រ) | 59,214 | 62,666 | 62,424 | 66,422 | 62,525 | 62,775 | 62,588 | 62,669 | 63,575 | 65,500 | 65,563.0 | 65,875.0 | 66,313.0 | 67,250.0 | 68,144.0 | 67,575.0 | 68,000 | 0.63 | 8.1 |
| ៩ | អុស (៛/១បាច់) | 1,207 | 1,189 | 1,271 | 1,382 | 1,306 | 1,331 | 1,338 | 1,338 | 1,359 | 1,353 | 1,363.0 | 1,350.0 | 1,356.0 | 1,381.0 | 1,413.0 | 1,438.0 | 1,425 | -0.9 | 8.4 |

សញ្ញា ∅ : មធ្យមភាគ

# តារាងទី ២ : ស្ថានភាពថវិកាជាតិ

គិតជាប៊ីលានរៀល

| ល.រ | សូចនាករ | 2018 | 2019 | 2020 | 2021 ø ខែ | 2021 ø ច្បាប់ថវិការ | 2021 សមមាត្រ | 2020 ត្រីមាស១ | 2020 ត្រីមាស២ | 2020 ត្រីមាស៣ | 2020 ត្រីមាស៤ | 2021 ត្រីមាស១ | 2021 ត្រីមាស២ | 2021 ត្រីមាស៣ | %Δធៀបនឹង ត្រីមាស មុន | %Δធៀបនឹង ត្រីមាស ដូចគ្នាឆ្នាំមុន | បមាណភាគ ត្រីមាស៣/២០២១ |
|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|
| | ការអនុវត្តច្បាប់ថវិកាគិតជា% | 112% | 128% | 110% | | | | | | | | | | | | | |
| | ច្បាប់ហិរញ្ញវត្ថុ | 17,890 | 20,036 | 20,785 | | | | | | | | | | | | | |
| ១ | I. ចំណូលថវិកាជាតិ | 19,956 | 25,652.5 | 22,870.0 | 1,431.6 | 1,732.1 | 82.7% | 5,544.1 | 5,699.5 | 5,224.9 | 6,401.5 | 6,095.5 | 5,510.9 | 4,294.8 | -22.1 | -17.8 | 1.00 |
| ២ | I.១. ចំណូលមូលធន | 406.5 | 630.0 | 1,842.0 | 8.8 | 36.9 | 23.9% | 20.2 | 161.2 | 1,074.8 | 585.8 | 988.3 | 71.6 | 26.5 | -62.9 | -97.5 | 0.01 |
| | I.៤. ចំណូលចរន្ត | 19,549.1 | 25,022.5 | 21,027.9 | 1,422.8 | 1,642.2 | 86.6% | 5,523.9 | 5,538.3 | 4,150.1 | 5,815.7 | 5,107.1 | 5,439.3 | 4,268.3 | -21.5 | 2.8 | 0.99 |
| ៣ | I.៤.១. ចំណូលសារពើពន្ធ * | 17,015.9 | 21,829.9 | 19,215.8 | 1,330.7 | 1,460.0 | 91.1% | 4,697.1 | 5,236.7 | 3,886.8 | 5,395.3 | 4,507.6 | 5,184.2 | 3,992.2 | -23.0 | 2.7 | 0.93 |
| | | 18,711.4 | 23,891.3 | 21,459.1 | 1,530.0 | _ | _ | 5,329.8 | 5,707.5 | 4,423.1 | 5,998.7 | 5,055.0 | 5,717.6 | 4,590.0 | -19.7 | 3.8 | 1.07 |
| | ១. ពន្ធ និងអាករគយ | 10,096.2 | 12,897.4 | 9,672.2 | 693.6 | 791.3 | 87.7% | 2,917.9 | 2,042.5 | 2,123.3 | 2,588.5 | 2,382.2 | 2,015.0 | 2,080.8 | 3.3 | -2.0 | 0.48 |
| | | 10,231.9 | 13,345.8 | 10,134.1 | 747.9 | _ | _ | 3,130.2 | 2,255.7 | 2,276.2 | 2,471.9 | 2,566.6 | 2,260.1 | 2,243.8 | -0.7 | -1.4 | 0.52 |
| | ១.១. ពន្ធគយ (របបនាំចូល) | 1,925.7 | 2,526.1 | 1,859.5 | 139.2 | _ | _ | 557.8 | 397.2 | 417.2 | 487.2 | 472.9 | 421.2 | 417.5 | -0.9 | 0.1 | 0.10 |
| | ១.២. អាករពិសេសលើរបបនាំចូល | 4,076.9 | 5,460.5 | 3,731.4 | 274.3 | _ | _ | 1,225.6 | 782.6 | 794.1 | 929.1 | 982.6 | 825.5 | 822.9 | -0.3 | 3.6 | 0.19 |
| | ១.៣. អាករលើតម្លៃបន្ថែម(របបនាំចូល) | 3,682.5 | 4,742.6 | 3,844.7 | 285.8 | _ | _ | 1,078.2 | 939.3 | 916.4 | 910.8 | 948.0 | 858.6 | 857.3 | -0.1 | -6.4 | 0.20 |
| | ១.៤. អាករនាំចេញ | 52.2 | 49.5 | 24.2 | 3.3 | _ | _ | 6.5 | 2.6 | 5.1 | 10.0 | 10.1 | 9.9 | 9.8 | -1.7 | 90.9 | 0.00 |
| | ១.៥. អាករបន្ថែមលើផលិតផលតេលសិល | 318.5 | 390.8 | 413.6 | 33.2 | _ | _ | 100.6 | 104.4 | 110.3 | 98.3 | 108.3 | 72.7 | 99.5 | 36.9 | -9.8 | 0.02 |
| | ១.៧. ផ្សេងៗ | 174.2 | 175.1 | 140.6 | 27.6 | _ | _ | 41.5 | 29.6 | 32.9 | 36.5 | 44.8 | 22.4 | 82.7 | 268.7 | 151.5 | 0.02 |
| ៤ | ២. ចំណូលពន្ធដារ | 6,919.7 | 8,932.5 | 9,543.6 | 637.6 | 668.7 | 95.4% | 1,779.1 | 3,194.2 | 1,763.5 | 2,806.8 | 2,125.3 | 3,169.2 | 1,912.8 | -39.6 | 8.5 | 0.45 |
| | | 8,479.6 | 10,545.4 | 11,325.1 | 782.1 | 757.0 | 103.3% | 2,199.6 | 3,451.8 | 2,146.9 | 3,526.8 | 2,488.4 | 3,457.4 | 2,346.2 | -32.1 | 9.3 | 0.55 |
| | ២.១. ពន្ធលើប្រាក់បៀវត្ស | 682.2 | 801.4 | 906.7 | 77.0 | 62.5 | 123.2% | 216.2 | 189.6 | 157.3 | 343.6 | 262.3 | 250.6 | 231.0 | -7.8 | 46.8 | 0.05 |
| | ២.២. ពន្ធលើប្រាក់ចំណូល | 3,204.9 | 3,964.7 | 6,130.1 | 295.0 | 296.2 | 99.6% | 693.7 | 3,504.2 | 780.6 | 1,151.6 | 955.9 | 2,169.2 | 885.1 | -59.2 | 13.4 | 0.21 |
| | ២.៤. អាករលើតម្លៃបន្ថែម | 2,026.2 | 2,505.6 | 2,588.6 | 192.9 | 220.0 | 87.7% | 600.6 | 523.6 | 589.8 | 874.6 | 610.9 | 543.1 | 578.8 | 6.6 | -1.9 | 0.13 |
| | ២.៥. អាករពិសេស | 853.8 | 1,058.6 | 995.2 | 60.3 | 78.8 | 76.6% | 267.6 | 222.4 | 185.1 | 320.0 | 253.5 | 172.9 | 180.9 | 4.6 | -2.3 | 0.04 |
| | ២.៦. ចំណូលផ្សេងៗ | 150.9 | 157.6 | 223.7 | 12.0 | 11.3 | 106.2% | 35.1 | 38.4 | 35.5 | 114.8 | 38.4 | 32.8 | 35.9 | 9.3 | 1.1 | 0.01 |
| | ២.៧. ថវិកាខេត្ត-រាជធានី | 1,550.3 | 2,048.1 | 1,894.8 | 144.1 | 87.5 | 164.7% | 419.0 | 359.6 | 396.6 | 719.6 | 238.9 | 286.9 | 432.4 | 50.7 | 9.0 | 0.10 |
| ៥ | I.៤.២. ចំណូលមិនមែនសារពើពន្ធ | 2,529.2 | 3,192.6 | 1,812.1 | 91.5 | 182.2 | 50.2% | 826.8 | 301.6 | 263.3 | 420.4 | 599.6 | 255.4 | 274.6 | 7.5 | 4.3 | 0.06 |
| | ១. កាស៊ីណូ | 167.6 | 344.7 | 163.8 | 0.5 | 16.5 | _ | 121.4 | 17.3 | 6.7 | 18.3 | 1.4 | 0.0 | 1.4 | 16,166.6 | -79.1 | 0.00 |
| | ២. ចំណូលពីអាជ្ញាបណ្ណក្នុងស្រុក | 43.1 | 64.2 | 45.9 | 3.8 | 3.7 | 101.0% | 19.1 | 9.3 | 9.5 | 8.0 | 70.3 | 2.8 | 11.3 | 305.2 | 19.5 | 0.00 |
| | ៣. កម្រៃការគ្រប់គ្រង និងទិដ្ឋាការនាំចេញ | 44.8 | 46.0 | 13.7 | 1.2 | 1.7 | 69.4% | 2.1 | 5.7 | 2.4 | 3.5 | 3.1 | 3.8 | 3.5 | -8.3 | 46.8 | 0.00 |
| | ៤. នេសាទ | 1.4 | 1.6 | 0.9 | 0.0 | _ | _ | 0.2 | 0.4 | 0.1 | 0.2 | 0.0 | 0.0 | 0.0 | _ | -100.0 | 0.00 |

សម្គាល់: លេខទ្រេតជាតួលេខរបស់រតនាគារជាតិ      សញ្ញា ø : មធ្យមភាគ

ចំពោះចំណូលពន្ធដារមានពីរជួរ: ជួរលេខទ្រេតជាតួរលេខរបស់រតនាគាជាតិដែលគិតតែតួរលេខថ្នាក់ជាតិ រីឯជួរលេខត្រង់ឈជាតួរលេខរបស់អគ្គនាយកដ្ឋានពន្ធដារ = ថ្នាក់ជាតិ + ថ្នាក់ក្រោមជាតិ

# តារាងទី ២ : ស្ថានភាពថវិកាជាតិ

គិតជាប៊ីលានរៀល

| ល.រ | សូចនាករ | 2017 | 2018 | 2019 | 2020 | 2021 | | | 2020 | | | | 2021 | | | Δ%ធៀបនឹងត្រីមាស | | បមាណភាគ |
|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|
| | | | | | | ៩ខែ | ៩ ច្បាប់ថវិការ | សមមាត្រ | ត្រីមាស១ | ត្រីមាស២ | ត្រីមាស៣ | ត្រីមាស៤ | ត្រីមាស១ | ត្រីមាស២ | ត្រីមាស៣ | មុន | ដូចគ្នាឆ្នាំមុន | ត្រីមាសទី៣ |
| ៦ | ៥. វត្តាប្រមាញ់ | 22.0 | 9.3 | 17.3 | 10.1 | 1.3 | 0.8 | 159% | 1.9 | 1.3 | 5.7 | 1.2 | 5.8 | 3.8 | 3.8 | 0.3 | -33.9 | 0.001 |
| | ៦. សម្បទានរ៉ែ | 34.6 | 53.0 | 64.0 | 76.9 | 6.1 | 8.3 | 74% | 14.7 | 24.1 | 15.7 | 22.4 | 9.9 | 15.9 | 18.3 | 15.6 | 17.0 | 0.004 |
| | ៧. អាកាសចរណ៍ស៊ីវិល | 128.2 | 141.1 | 212.1 | 132.8 | 1.5 | 10.9 | 13% | 66.9 | 21.1 | 11.6 | 33.2 | 5.4 | 4.8 | 4.4 | -9.0 | -62.4 | 0.001 |
| | ៨. ផលទុននៃសកម្មភាពទេសចរណ៍ | 415.7 | 422.6 | 375.8 | 80.2 | 0.10 | 16.5 | 0.6% | 76.73 | 0.69 | 1.67 | 1.12 | 0.89 | 0.37 | 0.3 | -17.7 | -81.6 | 0.000 |
| | ៩. ប្រៃសណីយ៍ និងទូរគមនាគមន៍ | 90.1 | 116.3 | 170.0 | 186.5 | 18.0 | 23.5 | 76% | 21.48 | 33.30 | 50.18 | 81.58 | 56.98 | 29.53 | 54.0 | 82.8 | 7.6 | 0.013 |
| | ១១.ការត្រួតពិនិត្យគុណភាពផលិតផល | 85.5 | 82.8 | 49.6 | 38.4 | 3.7 | 3.1 | 118% | 7.0 | 7.7 | 9.2 | 14.5 | 6.8 | 6.3 | 11.0 | 74.3 | 19.7 | 0.003 |
| | ១២.ជួលសហគ្រាស. សម្ភារ: ម.ធ.ដ.ជ.ន | 15.5 | 24.6 | 29.5 | 24.5 | 1.6 | 2.5 | 66% | 11.1 | 3.4 | 6.2 | 3.8 | 10.6 | 3.2 | 4.9 | 53.5 | -21.4 | 0.001 |
| | ១៣.ឯកជនភាវូបនីយកម្ម ស.ហ.គ.ស.ធ.ណ. | 0.0 | – | – | – | – | – | – | – | – | – | – | – | – | – | – | – | – |
| | ១៤.ការលក់អចលនកម្ម (ទ្រព្យសម្បត្តិរដ្ឋ) | 0.0 | – | – | – | – | – | – | – | – | – | – | – | – | – | – | – | – |
| | ១៥. ចំណូលផ្សេងៗទៀតពុំមែនសារពើពន្ធ | 745.9 | – | – | – | – | – | – | – | – | – | – | – | – | – | – | – | – |
| ៧ | ពន្ធ និងអាករជាបន្ទុករដ្ឋ | 7,838 | 8,693 | 9,553 | 10,114 | 1095.8 | – | – | 2677.0 | 2145.5 | 2371.3 | 2920.1 | 2714.7 | 3081.3 | 3287.4 | 6.69 | 38.6 | – |
| | ចំពោះការនាំចូល | 7,796 | 8,631 | 9,507 | 10,045 | 1087.1 | – | – | 2664.0 | 2132.7 | 2352.7 | 2896.2 | 2692.9 | 3058.4 | 3261.2 | 6.63 | 38.6 | – |
| ៨ | II. ចំណាយថវិកាជាតិ | 14,316 | 16,828 | 18,740 | 22,326 | 2110.9 | 1791.5 | 118% | 4783.9 | 5254.4 | 5113.2 | 7174.5 | 5366.4 | 4745.8 | 6332.6 | 33.4 | 23.8 | 1.0 |
| ៩ | II.១. ចំណាយចរន្ត | 12,088 | 14,076 | 14,552 | 16,497 | 1522.4 | 1160.0 | 131% | 3896.0 | 4053.5 | 3767.6 | 4779.9 | 3568.6 | 3685.3 | 4567.1 | 23.9 | 21.2 | 0.7 |
| | មធ្យោបាយ និងសេវា | 8,982 | 10,411 | 9,549 | 10,615 | 825.6 | 637.8 | 129% | 2305.2 | 2443.0 | 2762.5 | 3104.2 | 2058.7 | 2279.0 | 2476.7 | 8.7 | -10.3 | 0.4 |
| | បន្ទុកហិរញ្ញវត្ថុ | 234 | 392 | 442 | 484 | 60.6 | 51.8 | 117% | 165.7 | 40.9 | 188.7 | 89.2 | 188.6 | 44.5 | 181.9 | 309.2 | -3.6 | 0.0 |
| | អន្តរាគមន៍សាធារណៈ | 2,324 | 2,803 | 4,092 | 4,870 | 616.0 | 400.1 | 154% | 1220.2 | 1427.9 | 688.6 | 1532.9 | 1203.8 | 1336.9 | 1848.1 | 38.2 | 168.4 | 0.3 |
| | ចំណាយផ្សេងៗ | 451 | 471 | 469 | 1,013 | 20.2 | 12.3 | 164% | 689.5 | 141.8 | 127.8 | 53.6 | 117.5 | 25.1 | 60.5 | 141.3 | -52.7 | 0.0 |
| | ចំណាយតាមដីកា | – | – | – | – | – | – | – | – | – | – | – | – | – | – | – | – | – |
